**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១៧៨៤ អ.ក
ចុះថ្ងៃទី២៩-វិច្ឆិកា-២០២២
សាលក្រមព្រហ្មទណ្ឌលេខ: **៦៣ (ខ)**
ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

-បានបើកសវនាការជាអសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកណ្ដាល នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង០៩ព្រឹក ដោយមានសមាសភាពដូចតទៅ÷

### ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

- លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

- លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៧៨៤ អ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ÷

១- ឈ្មោះ [redacted] រតនា ហៅគ្រិច ភេទប្រុស អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរតែកុងឡាន ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សឿន(រស់) ម្ដាយឈ្មោះ [redacted] ចាន់រឿន (រស់) នៅលីវ កម្រិតវប្បធម៌មិនចេះអក្សរ ជានីតិជន ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២)**

២- ឈ្មោះ [redacted] សាន្ត ហៅម៉ៅ ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុង(រស់) ម្ដាយឈ្មោះ [redacted] ច្រឹប (ស្លាប់) នៅលីវ កម្រិតវប្បធម៌មិនចេះអក្សរ ជានីតិជន ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២)**

៣- ឈ្មោះ [redacted] សុខផល្លា ហៅឡា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៥) សញ្ជាតិខ្មែរ មុខរបរកម្មករបេក់ទឹកកក ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុខហេង (រស់) ម្ដាយឈ្មោះ [redacted] ស្រីលីន (រស់) នៅលីវ កម្រិតវប្បធម៌មិនចេះអក្សរ ជាអនីតិជន ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២)**

៤- ឈ្មោះ [redacted] សុខាវ ភេទប្រុស អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៧) សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុឃឿន (រស់) ម្ដាយឈ្មោះ [redacted] ស្រីទូច (រស់) នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៦ ជាអនីតិជន ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២)** na



Scanned with CamScanner

៥- ឈ្មោះ [redacted] ឧស្សា ហៅអ៊ូ ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៥) សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] តីមលាង (រស់) ម្តាយឈ្មោះ [redacted] ផល្លី (រស់) នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៦ ជាអនីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

៦- ឈ្មោះ [redacted] រតនៈ ហៅកែប ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ទឹកកក ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សឿន (រស់) ម្តាយឈ្មោះ [redacted] ចាន់រឿន (រស់) ប្រពន្ធឈ្មោះ [redacted] សូយ៉ា (រស់) មានកូនចំនួន០១នាក់ ជាអនីតិជន ទោសពីមុនគ្មាន។ (គេចខ្លួន)

-ជាប់ចោទពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិព្រែកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងឈ្មោះ [redacted] រតនៈ ហៅកែប។

-ដើមបណ្តឹងរដ្ឋប្បវេណី÷

១- ឈ្មោះ [redacted] កុសល់ ភេទប្រុស អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអ្នករត់កង់បី ទីលំនៅបច្ចុប្បន្នភូមិស្លែងដីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល។

២- ឈ្មោះ [redacted] សំអន ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្នភូមិព្រែកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល។

៣- ឈ្មោះ [redacted] វណ្ណឌី ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងម៉ាស៊ីនត្រជាក់ ទីលំនៅបច្ចុប្បន្នភូមិស្លែងដីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ២៨១ ដកសព ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៣០២ ដកជស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ៣៩៩ ដកចស/២៣ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## ***អង្គហេតុមានដូចតទៅ***

-កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង០៦ និង៣០នាទី ស្ថិតនៅភូមិព្រែកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ជនរងគ្រោះឈ្មោះ [redacted] កុសល់ ត្រឡប់មកពីរត់រ៉ឺម៉កកង់បីវិញ ហើយបានយករ៉ឺម៉កកង់បីទុកនៅកាំជណ្តើរមុខផ្ទះ រួចក៏បានចូលទៅសម្រាក បន្ទាប់មកនៅវេលាម៉ោង០១យប់ ជនរងគ្រោះបានចុះមកបត់ជើងតូច ឃើញថាបាត់រ៉ឺម៉កកង់បីរបស់ខ្លួន ជនរងគ្រោះបានទៅដាសល់ក្មួយប្រុសឱ្យជួយតាមរកតែរកមិនឃើញក៏ត្រឡប់មកផ្ទះវិញ និងបានរាយការណ៍ទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំព្រែកតាទែន។ លុះដល់



Scanned with CamScanner

ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង១៤ និង០០នាទី ឈ្មោះ [redacted]រ៉ា បានឃើញឈ្មោះ [redacted] សាន្ត ហៅម៉ៅ កំពុងជិះម៉ូតូឌុបគ្នា ហើយបានសួរនាំថា បានលួចម៉ូតូរ៉ឺម៉កកង់បីរបស់ឈ្មោះ [redacted] កុសល់ ឬអត់? ពេលនោះ ឈ្មោះ [redacted] សាន្ត ហៅម៉ៅ បានឆ្លើយថា ខ្លួនពិតជាបានលួចម៉ូតូរ៉ឺម៉កកង់បីរបស់ឈ្មោះ [redacted] កុសល់ រួចក៏បាន ធ្វើការឃាត់ខ្លួនប្រគល់ជូនសមត្ថកិច្ចតែម្តង។ នៅចំពោះមុខសមត្ថកិច្ចជនសង្ស័យឈ្មោះ [redacted] សាន្ត ហៅម៉ៅ បានសារភាពថា បក្ខពួករបស់ខ្លួនមានគ្នាចំនួន០៦នាក់មានឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សុខផល្លា ហៅឡា, ឈ្មោះ [redacted] សុខាវ, ឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងឈ្មោះ [redacted] រតនៈ ហៅកែប។ ក្រោយមកកម្លាំងជំនាញ សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកតាទែន និងប៉ុស្តិ៍នគរបាលរដ្ឋបាលពញាឮ បន្តស្រាវជ្រាវ ឃាត់ខ្លួនជនសង្ស័យបានចំនួន០៣នាក់បន្ថែមទៀតមានឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ ចំណែកឯឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងឈ្មោះ [redacted] រតនា ហៅកែប បានរត់ គេចខ្លួនបាត់។ នៅចំពោះមុខសមត្ថកិច្ចជនសង្ស័យទាំង០៣នាក់ខាងលើ បានឆ្លើយសារភាពថា ខ្លួនបានធ្វើ សកម្មភាពលួចចំនួន០៣លើកមកហើយ ដោយលួចរ៉ឺម៉កបានចំនួន០២គ្រឿង និងម៉ូតូចំនួន០២គ្រឿង។

<u>**ពេលសវនាការ**</u>

-ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១២យប់ ខ្លួនរួមជាមួយឈ្មោះ សុខាវ, ឈ្មោះ [redacted] សាន្ត និងឈ្មោះ ផល្លាបាននាំគ្នាជិះម៉ូតូចំនួន ០២គ្រឿងចេញពីផ្ទះនៅឃុំព្រែកតាទែន ក្នុងគោលបំណងដើរលួចរបស់គេ ពេលជិះមកដល់វត្តថ្មី ស្រាប់តែ ឃើញមានម៉ូតូសណ្តោងរ៉ឺម៉កចំនួន០១គ្រឿង ដែលទុកនៅមុខផ្ទះ ខណៈពេលនោះពួកខ្លួនបានចូលទៅលួចម៉ូតូ សណ្តោងរ៉ឺម៉កនោះ ហើយយកទៅលក់បានប្រាក់ចំនួន ១៣០$ (មួយរយសាមសិបដុល្លារអាមេរិច) ចំណែកឯ ឈ្មោះ អ៊ូ និងឈ្មោះ កែប ពុំបានចូលរួមធ្វើសកម្មភាពលួចនោះទេ ។ កន្លងមកខ្លួនធ្លាប់ធ្វើសកម្មភាពលួចចំនួន ០២ដងមកហើយ នៅពេលសមត្ថកិច្ចឃាត់ខ្លួនពុំមានបានដកហូតអ្វីពីខ្លួននោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] សាន្ត ហៅម៉ៅ បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១២យប់ ខ្លួន រួមជាមួយឈ្មោះ សុខាវ, ឈ្មោះ ក្រិច និងឈ្មោះ ផល្លា បាននាំគ្នាជិះម៉ូតូចំនួន ០២គ្រឿងចេញពីផ្ទះនៅឃុំព្រែកតាទែន ក្នុងគោលបំណងដើរលួចរបស់គេ ពេលជិះមកដល់វត្តថ្មី ស្រាប់តែឃើញ មានម៉ូតូសណ្តោងរ៉ឺម៉កចំនួន០១គ្រឿង ដែលទុកនៅមុខផ្ទះ ខណៈពេលនោះពួកខ្លួនបានចូលទៅលួចម៉ូតូ សណ្តោងរ៉ឺម៉កនោះ រួចជិះឡើងមកភ្នំពេញដើម្បីយកទៅលក់ ចំណែកឯឈ្មោះ អ៊ូ និងឈ្មោះ កែប ពុំបានចូលរួម ធ្វើសកម្មភាពលួចនោះទេ។ កន្លងមកខ្លួនធ្លាប់ធ្វើសកម្មភាពលួចចំនួន០៣ដងមកហើយ នៅពេលសមត្ថកិច្ច ឃាត់ខ្លួនដកហូតទូរស័ព្ទម៉ាក OPPO ពណ៌ក្រហម ចំនួន០១គ្រឿង។

-ជនជាប់ចោទឈ្មោះ [redacted] សុខផល្លា ហៅឡា បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល០២រំលងអាធ្រាត ខ្លួនរួមជាមួយឈ្មោះ សឿន រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត និងឈ្មោះ ខាវ បាននាំគ្នាជិះម៉ូតូចំនួន០២គ្រឿងម៉ាក HONDA DREAM សេរីឆ្នាំ២០១២ និងម៉ាក HONDA DREAM សេរីឆ្នាំ ២០០៦ ក្នុងគោលបំណងដើរលួចរបស់គេ ពេលជិះមកដល់វត្តថ្មី ស្រាប់តែឃើញមានម៉ូតូសណ្តោងរ៉ឺម៉កចំនួន ០១គ្រឿង ដែលទុកនៅមុខផ្ទះ ខណៈពេលនោះពួកខ្លួនបានចូលទៅលួចម៉ូតូសណ្តោងរ៉ឺម៉កនោះ ពេលលួចរួច ពួកខ្លួនបានយកម៉ូតូសណ្តោងរ៉ឺម៉កនោះទៅលក់ ហើយចែកប្រាក់គ្នាក្នុងម្នាក់ៗបានចំនួន ៩០០០០៛(ប្រាំបួនម៉ឺនរៀល) ចំណែកឯឈ្មោះ អ៊ូ និងឈ្មោះ កែប ពុំបានចូលរួមធ្វើសកម្មភាពលួចនោះទេ។ កន្លងមកខ្លួនធ្លាប់ធ្វើសកម្មភាព លួចចំនួន០៣ដងមកហើយ នៅពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតទូរស័ព្ទម៉ាក OPPO ពណ៌ខ្មៅ ចំនួន០១គ្រឿង។

-ជនជាប់ចោទឈ្មោះ [redacted] សុខាវ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១២យប់ ខ្លួនរួមជាមួយឈ្មោះ គ្រិច, ឈ្មោះ [redacted] សាន្ត និងឈ្មោះ ផល្លា បាននាំគ្នាជិះម៉ូតូចំនួន០២គ្រឿង ចេញពីផ្ទះនៅឃុំព្រែកតាទែន ក្នុងគោលបំណងដើរលួចរបស់គេ ពេលជិះមកដល់វត្តថ្មី ស្រាប់តែឃើញមានម៉ូតូសណ្តោងរ៉ឺម៉កចំនួន០១គ្រឿង ដែលទុកនៅមុខផ្ទះ ខណៈពេលនោះពួកខ្លួនបានចូលទៅលួចម៉ូតូសណ្តោងរ៉ឺម៉កនោះ ហើយយកទៅលក់បានប្រាក់ចំនួន ១៣០$ (មួយរយសាមសិបដុល្លារអាមេរិច) ចំណែកឯឈ្មោះ អ៊ូ និងឈ្មោះ កែប ពុំបានចូលរួមធ្វើសកម្មភាពលួចនោះទេ។ កន្លងមកខ្លួនធ្លាប់ធ្វើសកម្មភាពលួចចំនួន០២ដងមកហើយ នៅពេលសមត្ថកិច្ចឃាត់ខ្លួនពុំមានបានដកហូតអ្វីពីខ្លួននោះទេ។ កន្លងមកខ្លួនធ្លាប់ធ្វើសកម្មភាពលួចចំនួន០៣ដងមកហើយ នៅពេលសមត្ថកិច្ចឃាត់ខ្លួនពុំមានបានដកហូតអ្វីពីខ្លួននោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ បានឆ្លើយដោះសារថា: ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ពេលនោះខ្លួនស្ថិតនៅផ្ទះពុំមានវត្តមាននៅកន្លែងកើតហេតុនោះទេ តែមុនពេលកើតហេតុខ្លួនបានជួបពួកគាត់ហូបចុកជុំគ្នារួចទើបបែកគ្នាទៅផ្ទះ តែខ្លួនមិនដឹងថាក្រុមពួកគាត់ចេញទៅលួចគេទេ។ ខ្លួនមិនដែលចូលរួមធ្វើសកម្មភាពលួចរបស់គេម្តងណានោះឡើយ។ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] រតនៈ ហៅកែប (គេចខ្លួន)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល់ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង២១ និង០០នាទី ខ្លួនបានយករ៉ឺម៉កកង់បីទៅទុកនៅជាប់កាំជណ្តើរមុខផ្ទះ ដោយពេលនោះខ្លួនបានយកមេសោរចាក់ជាប់ហ្វ្រាំងបូមកង់មុខ ហើយបានយកកូនសោរម៉ូតូកង់បី និងកូនសោរចាក់កង់មុខទៅទុកក្នុងផ្ទះ រួចខ្លួនបានចូលទៅដេកនៅក្នុងផ្ទះ។ បន្ទាប់មកនៅវេលាម៉ោង០១រំលងអាធ្រាត ឈានចូលថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួនបានងើបបត់ជើងតូច ស្រាប់តែបាត់មិនឃើញរ៉ឺម៉កកង់បី ពេលនោះខ្លួនបានដាស់ក្មួយឈ្មោះ វណ្ណា រស់នៅផ្ទះជិតគ្នាជិះម៉ូតូតាមរកនៅទិសខាងត្បូង ប៉ុន្តែរកមិនឃើញ ហើយបានត្រឡប់មកវិញចូលទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកតាទែន តែម្តង។ ក្នុងរឿងនេះខ្លួនសូមទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន ១៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិច)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំអន បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង០១ និង៣០នាទី ពេលដែលរថយន្តដឹកទឹកកកបើកមកទម្លាក់ទឹកកកនៅផ្ទះរបស់ខ្លួន ក្នុងនោះខ្លួនបានដើរចេញពីក្នុងផ្ទះមកក្រៅផ្ទះកន្លែងលក់ទឹកកក ស្រាប់តែមិនឃើញម៉ូតូរ៉ឺម៉កសណ្តោងទឹកកកដែលចតទុកនៅខាងមុខផ្ទះនៅលើផ្លូវបេតុង។ រហូតដល់វេលាម៉ោង០២ និង៣០នាទី ខ្លួន និងបងថ្លៃឈ្មោះ [redacted] តាយ បាននាំគ្នាជិះម៉ូតូចេញតាមរកក៏ប្រទះឃើញតែកន្ទុយរ៉ឺម៉កសណ្តោងទឹកកក ដែលគេយកមកទុកចោលនៅចំណុចភូមិទួលអំពិល ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល លុះព្រឹកឡើងខ្លួនបានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកតាទែន តែម្តង។ ក្នុងរឿងនេះខ្លួនសូមទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន ៥០០$ (ប្រាំរយដុល្លារអាមេរិច)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណឌី បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១៨ និង០០នាទី ឪពុករបស់ខ្លួនបានត្រឡប់មកដល់ផ្ទះវិញ ហើយបានយកម៉ូតូសណ្តោងរ៉ឺម៉កទុកនៅលើផ្លូវបេតុងនៅមុខផ្ទះ ស្ថិតនៅភូមិស្លែងជីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល បន្ទាប់មកឪពុករបស់ខ្លួនបានចូលហូបបាយ ហើយសម្រាកទៅ។ រហូតដល់វេលាម៉ោង០៦ និង០០នាទីព្រឹក ឪពុករបស់ខ្លួនបានចេញមកមុខផ្ទះពុំបានឃើញម៉ូតូសណ្តោងរ៉ឺម៉កនោះទេ ហើយខ្លួន និងឪពុក បាននាំគ្នាទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកតាទែន។ ក្នុងរឿងនេះខ្លួនសូមទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន ៩៥០$ (ប្រាំបួនរយហាសិបដុល្លារអាមេរិច)។



Scanned with CamScanner

-អំណានចម្លើយសាក្សីឈ្មោះ[redacted]រ៉ា បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១០ និង០០នាទី ខ្លួនដឹងថាឈ្មោះ សែម កុសល់ បានបាត់ម៉ូតូរ៉ឺម៉កកង់បីរបស់គាត់ ព្រោះខ្លួនឃើញឈ្មោះ [redacted] កុសល់ សុំកាមេរ៉ាសុវត្ថិភាពនៅដេប៉ូលក់ប្រេងសាំងតេឡានៅជិតផ្ទះគាត់មើល ហើយក្នុងពេលនោះខ្លួនបាននៅមើលភិនភាគចោរតាមរយៈកាំមេរ៉ាសុវត្ថិភាពនោះដែរ។ លុះដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១៥ និង០០នាទី ខ្លួនបានឃើញឈ្មោះ [redacted] សាន្ត ហៅម៉ៅ ភេទប្រុស អាយុប្រហែល១៧ឆ្នាំ រស់នៅក្នុងភូមិព្រែកក្ដី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្ដាល ដើរកាត់ភូមិរបស់ខ្លួនដែលមានភិនភាគដូចចោរដែរលួចម៉ូតូរ៉ឺម៉កកង់បីរបស់ឈ្មោះ [redacted] កុសល់។ ភ្លាមនោះខ្លួនបានឱបឈ្មោះ [redacted] សាន្ត ហៅម៉ៅ មកផ្ទះឈ្មោះ [redacted] កុសល់ ហើយនាំគ្នាសួរឈ្មោះ [redacted] សាន្ត ហៅម៉ៅ ទើបដឹងថាក្រុមចោរដែលលួចម៉ូតូរ៉ឺម៉កកង់បី គឺជាក្រុមរបស់ឈ្មោះ [redacted] សាន្ត ហៅម៉ៅ បន្ទាប់មកទើបពួកខ្លួនបានប្រគល់ឈ្មោះ [redacted] សាន្ត ហៅម៉ៅ ទៅឱ្យសមត្ថកិច្ចតែម្ដង។

-ក្រឡាបញ្ជីអានឯកសារនានានៅក្នុងសំណុំរឿងនេះ។

<u>**សិទ្ធិនិយាយស្ដីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**</u>

-តំណាងអយ្យការបានសន្និដ្ឋានថាៈ ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ នៅពេលសវនាការឃើញថាជនជាប់ចោទពិតជាបានធ្វើសកម្មភាពលួចម៉ូតូសណ្ដោងរ៉ឺម៉ករបស់ឈ្មោះ [redacted] កុសល់, ឈ្មោះ [redacted] សំអន និងឈ្មោះ [redacted] វណ្ណឌី កាលពីថ្ងៃទី១៩, ថ្ងៃទី២៤ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រាកដមែន។ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ពីបទៈ អំពើលួច ប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទ ចំពោះអង្គហេតុអំពើលួច កាលពីថ្ងៃទី១៩, ថ្ងៃទី២៤ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ បន្ថែមទៀត។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ បានធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីខ្លួនទាំងពីរនាក់បានឆ្លើយសារភាពទទួលស្គាល់កំហុសនៅគ្រប់ដំណាក់កាលនីតិវិធី ហើយកូនក្ដីខ្លួនទាំងពីរនាក់ជាអនីតិជន។ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះជួយបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនទាំងពីរនាក់ផង។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងឈ្មោះ [redacted] រតនៈ ហៅកែប បានធ្វើសេចក្ដីសន្និដ្ឋានថាៈ ក្រោយពីបានស្ដាប់ការពិភាក្សាសួរដេញដោល ឃើញថាកូនក្ដីខ្លួនទាំងពីរនាក់គ្រាន់តែបានចូលរួមហូបចុកជាមួយជនជាប់ចោទទាំងបួននាក់ប៉ុណ្ណោះ តែមិនបានចូលរួមលួចនោះទេ ហើយជនជាប់ចោទទាំងបួននាក់ បានឆ្លើយបញ្ជាក់ថា កូនក្ដីខ្លួនទាំងពីរនាក់មិនបានចូលរួមធ្វើសកម្មភាពលួចជាមួយពួកគេនោះទេ។ បើផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាវិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចដល់កូនក្ដីខ្លួនទាំងពីរនាក់ឱ្យរួចផុតពីបទចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ បានកត់សម្គាល់ដូចគ្នាថាៈ ពួកខ្លួនសំណូមពរដល់តុលាការជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ បានកត់សម្គាល់ថាៈ ខ្ញុំសំណូមពរដល់តុលាការលើកលែងចោទប្រកាន់ដល់រូបខ្ញុំផង។



Scanned with CamScanner

## ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ។

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល់, ឈ្មោះ [redacted] សំអន និងឈ្មោះ [redacted] វណ្ណឌី។

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted] រ៉ា។

-ក្រោយពីបានស្តាប់ការអានឯកសារនានា។

-ក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងឈ្មោះ [redacted] រតនៈ ហៅកែប។

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់។

## សំអាងហេតុ

## តុលាការយល់ឃើញថា

១- កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង០៦ និង៣០នាទីព្រឹក មានករណី **អំពើលួច** បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ ប្រព្រឹត្តនៅភូមិព្រែកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ពិតប្រាកដមែន។

២- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted]តនា ហៅក្រិច, ឈ្មោះ [redacted]សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ[redacted]សុខាវ បានឆ្លើយសារភាពដូចគ្នាថា: កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១២យប់ ពួកខ្លួនបាននាំគ្នាជិះម៉ូតូចំនួន០២គ្រឿងចេញពីផ្ទះនៅឃុំព្រែកតាទែន ក្នុងគោលបំណងដើរលួចរបស់គេ ពេលជិះមកដល់វត្តថ្មី ស្រាប់តែឃើញមានម៉ូតូសណ្តោងរ៉ឺម៉កចំនួន០១គ្រឿង ដែលទុកនៅមុខផ្ទះ ខណៈពេលនោះពួកខ្លួនបានចូលទៅលួចម៉ូតូសណ្តោងរ៉ឺម៉កនោះ ហើយយកទៅលក់បានប្រាក់ចំនួន ១៣០$ (មួយរយសាមសិបដុល្លារអាមេរិច) នឹងបានយកប្រាក់មកចែកគ្នា។ កន្លងមកពួកខ្លួនធ្លាប់ធ្វើសកម្មភាពលួចចំនួន០២ទៅ០៣ដងមកហើយ។ ចម្លើយសារភាពនេះមានលក្ខណៈស៊ីចង្វាក់ទៅនឹងចម្លើយជនជាប់ចោទនៅគ្រប់ដំណាក់កាលនីតិវិធី ស៊ីចង្វាក់ទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី វត្ថុតាង របាយការណ៍សរុប ឯកសារគតិយុត្តនានា ដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់បានថា ជនជាប់ចោទទាំងបួននាក់ ពិតជាបានធ្វើសកម្មភាពម៉ូតូរ៉ឺម៉កកង់បី និងម៉ូតូសណ្តោងរ៉ឺម៉ក របស់ជនរងគ្រោះឈ្មោះ [redacted] កុសល់, ឈ្មោះ [redacted] សំអន និងឈ្មោះ [redacted] វណ្ណឌី ប្រាកដមែន។

៣- ជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ បានឆ្លើយដោះសារថា: ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ពេលនោះខ្លួនស្ថិតនៅផ្ទះពុំមានវត្តមាននៅកន្លែងកើតហេតុនោះទេ តែមុនពេលកើតហេតុខ្លួនបានជួបពួកគាត់ហូបចុកជុំគ្នារួចទើបបែកគ្នាទៅផ្ទះ តែខ្លួនមិនដឹងថាក្រុមពួកគាត់ចេញទៅលួចគេទេ។ ខ្លួនមិនដែលចូលរួមធ្វើសកម្មភាពលួចរបស់គេម្តងណានោះឡើយ។ ចម្លើយដោះសារនេះមានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការជឿបាន បើផ្អែកតាមចម្លើយរបស់ជនជាប់ចោទទាំងបួននាក់ បានឆ្លើយបញ្ជាក់ដូចគ្នាថា: ឈ្មោះ [redacted] ឧស្សា ហៅអ៊ូ មិនបានចូលរួមធ្វើសកម្មភាពលួចជាមួយពួកខ្លួននោះទេ។



Scanned with CamScanner

៤- ជនជាប់ចោទឈ្មោះ [redacted] រតនៈ ហៅកែប អវត្តមាននៅគ្រប់ដំណាក់កាលនីតិវិធីពុំមានចម្លើយនៅក្នុងសំណុំរឿង ប៉ុន្តែបើផ្អែកតាមចម្លើយនាពេលសវនាការរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ បានឆ្លើយបញ្ជាក់ដូចគ្នាថា: ឈ្មោះ [redacted] រតនៈ ហៅកែប មិនបានចូលរួមសកម្មភាពប្រព្រឹត្តអំពើលួចជាមួយពួកខ្លួននោះទេ។

៥- តាមរបាយការណ៍សរុបលេខ: ០៤៨ របក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកពញាឮ បានសន្និដ្ឋានថា÷ ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ ពិតជាបានធ្វើសកម្មភាពលួចម៉ូតូសណ្តោងរ៉ឺម៉ក និងម៉ូតូកង់បី របស់ជនរងគ្រោះ ប្រាកដមែន។

៦- តាមកំណត់ហេតុ ទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកពញាឮ រួមមាន÷ ទុលវីស ដងធ្វើពីជ័រ ពណ៌ខ្មៅលាយលឿង ចំនួន០១។

៧- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ មានចេតនាទុច្ចរិតដកហូតនូវទ្រព្យសម្បត្តិអ្នកដ៏ទៃក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន គឺជាបទល្មើសព្រហ្មទណ្ឌបទ: **អំពើលួច** ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ។

៨- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងឈ្មោះ [redacted] រតនៈ ហៅកែប ពុំមានធាតុផ្សំគ្រប់គ្រាន់ពីបទ: **អំពើលួច** ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ។ ផ្អែកតាមមាត្រា **៣៨** នៃរដ្ឋធម្មនុញ្ញ និងមាត្រា **៣៥១** នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា: វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

៩- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទនៅពេលសវនាការឃើញថាជនជាប់ចោទពិតជាបានធ្វើសកម្មភាពលួចម៉ូតូសណ្តោងរ៉ឺម៉ករបស់ឈ្មោះ [redacted] កុសល់, ឈ្មោះ [redacted] សំអន និងឈ្មោះ [redacted] វណ្ណឌី កាលពីថ្ងៃទី១៩, ថ្ងៃទី២៤ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រាកដមែន។ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ពីបទ: អំពើលួច ប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ ចំពោះអង្គហេតុអំពើលួច កាលពីថ្ងៃទី១៩, ថ្ងៃទី២៤ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ បន្ថែមទៀត។ **តុលាការពិចារណាឃើញថា** ការប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ចំពោះការប្តឹងសុំឱ្យផ្តន្ទាទោសឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងឈ្មោះ [redacted] រតនៈ ហៅកែប ឃើញថាពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អាចឱ្យតុលាការសម្រេចផ្តន្ទាទោសតាមការប្តឹងសុំបានទេ។

១០- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនទាំងពីរនាក់បានឆ្លើយសារភាពទទួលស្គាល់កំហុសនៅគ្រប់ដំណាក់កាលនីតិវិធី ហើយកូនក្តីខ្លួនទាំងពីរនាក់ជាអនីតិជន។ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនទាំងពីរនាក់ផង។ **តុលាការពិចារណាឃើញថា** ជនជាប់ចោទទាំងពីរនាក់ជាអនីតិជន តុលាការសម្រេចផ្តន្ទាទោសដោយយោងតាមមាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ។ ចំពោះការស្នើសុំឱ្យតុលាការសម្រេចសម្រាលទោសឃើញថា មិនមានលក្ខខណ្ឌគ្រប់គ្រាន់អាចឱ្យតុលាការសម្រេចតាមការស្នើសុំបានទេ ព្រោះជនជាប់ចោទបានធ្វើសកម្មភាពលួចជាច្រើនដង។



Scanned with CamScanner

១១- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឧស្សា ហៅអ៊ួ និងឈ្មោះ [redacted] រតនៈ ហៅកែប បានធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានស្តាប់ការពិភាក្សាសួរដេញដោល ឃើញថាកូនក្តីខ្លួនទាំងពីរនាក់គ្រាន់តែបានចូលរួមហូបចុកជាមួយជនជាប់ចោទទាំងបួននាក់ប៉ុណ្ណោះ តែមិនបានចូលរួមលួចនោះទេ ហើយជនជាប់ចោទទាំងបួននាក់ បានឆ្លើយបញ្ជាក់ថា កូនក្តីខ្លួនទាំងពីរនាក់មិនបានចូលរួមធ្វើសកម្មភាពលួចជាមួយពួកគេនោះទេ។ បើផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាវិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។ ដូច្នេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចដល់កូនក្តីខ្លួនទាំងពីរនាក់ឱ្យរួចផុតពីបទចោទប្រកាន់។ តុលាការពិចារណាឃើញថា ការស្នើសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ និងមានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការសម្រេចតាមការស្នើសុំបាន។

១២- ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ ជានីតិជន, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ ជាអនីតិជន មានស្មារតីគ្រប់គ្រាន់ អាចទទួលខុសត្រូវនូវអំពើដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ពុំមានភស្តុតាងណាមួយ ដែលបញ្ជាក់ថាជនជាប់ចោទមានវិល្លាបស្មារតីនោះទេ ដូច្នេះជនជាប់ចោទទាំងបួននាក់មានសមត្ថភាពទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

១៣- ក្រោយពីបានពិនិត្យ នឹងពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើ÷ ឈ្មោះ [redacted] ឧស្សា ហៅអ៊ួ និងឈ្មោះ [redacted] រតនៈ ហៅកែប ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិព្រៃកក្តិ ឃុំព្រៃកតាទែន ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការសម្រេចឱ្យរួចខ្លួនពីបទចោទ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៤- ក្រោយពីបានពិនិត្យ នឹងពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើ÷ ឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិព្រៃកក្តិ ឃុំព្រៃកតាទែន ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៩, ថ្ងៃទី២៤ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១៥- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ របៀបរៀបរយសង្គម និងច្បាប់របស់រដ្ឋ។

១៦- ជនជាប់ចោទឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ ជាអនីតិជន។ ដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោស ដោយអនុវត្តតាមមាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ។

១៧- វត្ថុតាង÷ ទុលវីស ដងធ្វើពីជ័រ ពណ៌ខ្មៅលាយលឿង ចំនួន០១ និងទូរស័ព្ទដៃម៉ាក OPPO ពណ៌ក្រហម ចំនួន០១គ្រឿង គប្បីតុលាការសម្រេចរឹបអូស តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

១៨- ដើមបណ្តឹងរដ្ឋប្បវេណី÷

ក. ឈ្មោះ [redacted] កុសល់ បានទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន ១៥០០$ ( មួយពាន់ប្រាំរយដុល្លារអាមេរិច)។

ខ. ឈ្មោះ [redacted] សំអន បានទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន ៥០០$ (ប្រាំរយដុល្លារអាមេរិច)។

គ. ឈ្មោះ [redacted] វណ្ណនី បានទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន ៩៥០$ (ប្រាំបួនរយហាសិបដុល្លារអាមេរិច)។

ឃើញថាមានលក្ខណៈត្រឹមត្រូវច្បាប់ គប្បីតុលាការសម្រេចឱ្យជនជាប់ចោទរួមគ្នាសងសំណងការខូចខាត និងជម្ងឺចិត្ត ដោយសាមគ្គីតាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមមាត្រា ១៤ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>សេចក្តីសម្រេច</u>**

១- ឱ្យឈ្មោះ [redacted] ឧស្សា ហៅអ៊ូ ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៥) សញ្ជាតិខ្មែរ និងឈ្មោះ [redacted] រតនៈ ហៅកែប ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ រួចខ្លួនពីបទចោទ បទ: អំពើលួច ប្រព្រឹត្តនៅភូមិព្រែកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៩, ថ្ងៃទី២៤ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ផ្តន្ទាទោស÷

ក. ឈ្មោះ [redacted] រតនា ហៅក្រិច ភេទប្រុស អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ (មួយ)ឆ្នាំ ០៦ (ប្រាំមួយ)ខែ។

ខ. ឈ្មោះ [redacted] សាន្ត ហៅម៉ៅ ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ (មួយ)ឆ្នាំ ០៦ (ប្រាំមួយ)ខែ។

គ. ឈ្មោះ [redacted] សុខផល្លា ហៅឡា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៥) សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៩ (ប្រាំបួន)ខែ។

ឃ. ឈ្មោះ [redacted] សុខាវ ភេទប្រុស អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៧) សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៩ (ប្រាំបួន)ខែ។

ពីបទ: អំពើលួច ប្រព្រឹត្តនៅភូមិព្រែកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៩, ថ្ងៃទី២៤ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦ និងមាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ។

៣- វត្ថុតាង÷ ទុយោរីស ដងធ្វើពីដែក ពណ៌ខ្មៅលាយលឿង ចំនួន០១ និងទូរស័ព្ទដៃម៉ាក OPPO ពណ៌ក្រហម ចំនួន០១គ្រឿង សម្រេចរឹបអូស តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៤- បង្គាប់ឱ្យ÷

ក. ឈ្មោះ [redacted] រតនា ហៅក្រិច ភេទប្រុស អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] សាន្ត ហៅម៉ៅ ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ។

ខ. ឈ្មោះ [redacted] សុខផល្លា ហៅឡា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៥) សញ្ជាតិខ្មែរ និងឈ្មោះ [redacted] សុខាវ ភេទប្រុស អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៧) (និងអាណាព្យាបាល)។



Scanned with CamScanner

រួមគ្នាសងសំណងការខូចខាត និងជម្ងឺចិត្តឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីដូចខាងក្រោម÷

- ឈ្មោះ [redacted] កុសល់ ចំនួន ១៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិច)។
- ឈ្មោះ [redacted] សំអន ចំនួន ៥០០$ (ប្រាំរយដុល្លារអាមេរិច)។
- ឈ្មោះ [redacted] វណ្ណឌី ចំនួន ៩៥០$ (ប្រាំបួនរយហាសិបដុល្លារអាមេរិច)។

តាមមាត្រា ១៤, មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា **៧៤៦ កថាខណ្ឌទី២** នៃក្រមរដ្ឋប្បវេណី។

-សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រតនា ហៅក្រិច, ឈ្មោះ [redacted] សាន្ត ហៅម៉ៅ, ឈ្មោះ [redacted] សុខផល្លា ហៅឡា, ឈ្មោះ [redacted] សុខាវ, ឈ្មោះ [redacted] ឧស្សា ហៅអ៊ូ និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល់, ឈ្មោះ [redacted] សំអន, ឈ្មោះ [redacted] វណ្ណឌី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រតនៈ ហៅកែប និងអាណាព្យាបាលរបស់ឈ្មោះ [redacted] សុខផល្លា ហៅឡា និងឈ្មោះ [redacted] សុខាវ ជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងប្រកាសជាអសាធារណៈនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។ ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា និងត្រា: |
| [redacted] | | | |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្ដាល, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

កណ្ដាល, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner